ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

# ស្ត្រីចូលរួមនយោបាយក្នុងការបោះឆ្នោត

(ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២ ឆ្ពោះទៅការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣)

ស្ត្រីដែលចូលរួមក្នុងនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២ កន្លងមកត្រូវបានរកឃើញថា នៅតែមានភាពប្រឈមរាប់ចាប់ពីការចូលរួមការបោះឆ្នោត ឱកាសក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោត និងឱកាសឈានទៅមុខក្នុងជីវិតនយោបាយរបស់ស្ត្រីជាប់ឆ្នោត។ តាំងពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់២០០២ មានការកើនឡើងចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ជាបន្តបន្ទាប់ ជាពិសេសស្ត្រីក្នុងកិច្ចការនយោបាយ និងការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន។

រាប់ចាប់ពីឆ្នាំ២០០២ នៃការចាប់ផ្តើមអនុវត្តនយោបាយវិមជ្ឈការរបស់ប្រទេសកម្ពុជាតាមរយៈការបោះឆ្នោត ស្ត្រីចូលរួមក្នុងនយោបាយ និងស្ត្រីជាប់ឆ្នោតនៅតែមានការកើនឡើងតិចតួចបើគិតត្រឹមពាក់កណ្តាលឆ្នាំ២០១២។ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី១ (ឆ្នាំ២០០២-២០០៧) ក្នុងចំណោមអាសនៈក្រុមប្រឹក្សាឃុំ-សង្កាត់សរុប ១១,២៦១អាសនៈ(១៦២១ឃុំ-សង្កាត់) ស្ត្រីនៅចុងអាណត្តិមានសរុប ៨.៧២% ហើយនៅចុងអាណត្តិទី២(ឆ្នាំ២០០៧-២០១២) ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់កើនដល់ ១៦.០៨%នៃអាសនៈសរុប ១១,៣៥៣អាសនៈ។ តាមលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣ (ឆ្នាំ២០១២-២០១៧) ដែលបានប្រកាសជាផ្លូវការដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ មានស្ត្រីប្រមាណ២,០៣៨ នាក់ (ស្មើនឹង ១៧.៧៨%) បានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ស្ត្រីអាណត្តិទី៣ ក្នុងចំណោមមន្ត្រីជាប់ឆ្នោតទាំងបុរស-ស្ត្រីសរុប ១១, ៤៥៩នាក់ (១៦៣៣ឃុំ-សង្កាត់) ។ តួលេខនេះបង្ហាញថា កម្ពុជាមានការប្រឈមក្នុងការធ្វើឱ្យបានសម្រេចតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(CMDG) ដែលកម្ពុជាបានកំណត់ថា នៅឆ្នាំ២០១៥ មន្ត្រីជាប់ឆ្នោតជាស្ត្រីនៅថ្នាក់ឃុំ-សង្កាត់យ៉ាងតិច ២៥%។

យោងតាមរបាយការណ៍ UNDP’s Human Development Index 2011-Gender Inequality Index (GII)[1] កម្ពុជានៅតែមានការបន្ថយវិសមភាពយេនឌ័រប្រសើរឡើងពី ០.៦០ នៅឆ្នាំ២០០០ មកដល់ឆ្នាំ២០១១ នៅត្រឹម ០.៥០ ប៉ុន្តែកម្រិតទាបនៃសមធម៌យេនឌ័រគឺនៅត្រឹមលេខ ៩៩ (ក្នុងចំណោមលេខអន់បំផុត១៤៦) ក្នុងចំណោមប្រទេសដែលមានចំណាត់ថ្នាក់ទាបជាងគេនៅអាស៊ីអាគ្នេយ៍ ដូចគ្នានឹង ប្រទេសភូមា ប្រទេសឡាវ និងប្រទេសឥណ្ឌូនេស៊ីដែរ។

ការកើនឡើងចំនួនស្ត្រីក្នុងកិច្ចការនយោបាយនេះ ដោយសារមានការខិតខំរួមចំណែកពីគណបក្សនយោបាយ រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយ សហគមន៍អន្តរជាតិ ក្នុងការបង្កើនសមត្ថភាព និងគាំទ្រស្ត្រី។

[1] UNDP: Human Development Index 2011-Gender Inequality Index (GII), www.undp.org.kh

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.**
**P.O. Box**1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

ម៉្យាងទៀត សង្គមកម្ពុជាក៏មានការកែប្រែឥរិយាបថខ្លះក្នុងការមិនរើសអើងប្រឆាំងនឹងស្ត្រី។ មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣ និងមុនការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត លោកនាយករដ្ឋមន្ត្រី ព្រមទាំងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា បានអំពាវនាវទៅគណបក្សនយោបាយដាក់ស្ត្រីឈរឈ្មោះបោះឆ្នោតនៅលេខរៀងខាងលើ។ ប៉ុន្តែការប្រឈមរបស់ស្ត្រីក៏បន្តនៅមានក្នុងការចូលរួមបោះឆ្នោត និងកិច្ចការនយោបាយ។

យោងតាមលទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣នេះ មានបេក្ខជនប្រកួតប្រជែងសរុបចំនួន១១១០៥៦នាក់ (បេក្ខជនពេញសិទ្ធិ) ក្នុងនោះ បេក្ខជនស្ត្រីមានចំនួន ២៨ ៤៨១នាក់ (២៥,៦៤%) មកពីគណបក្សនយោបាយចំនួន ១០ និងមានតែគណបក្សប្រជាជនកម្ពុជាតែមួយគត់ដែលបានរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនៅទូទាំងប្រទេស ១៦៣៣ ឃុំ-សង្កាត់។ ចំនួនបេក្ខនារីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣ មានការកើនឡើងពី ១៦% ក្នុងឆ្នាំ២០០២ (សរុបក្នុងចំណោម ៨គណបក្សនយោបាយ) ទៅ ២១,៣៦% ក្នុងឆ្នាំ២០០៧ (សរុបក្នុងចំណោម ១២គណបក្សនយោបាយ) ហើយបន្តកើនដល់ ២៥,៦៤% ក្នុងឆ្នាំ២០១២ (ក្នុងចំណោម ១០គណបក្សនយោបាយ)។ តួលេខនេះ មានការកើនឡើងចំនួន ៤,២៨% ពី ២១,៣៦% (អាណត្តិទី២ ឆ្នាំ២០០៧) ទៅ ២៥,៦៤% (អាណត្តិទី៣ ឆ្នាំ២០១២)។ លទ្ធផលបោះឆ្នោតបានបង្ហាញថា ខេត្តប៉ៃលិន និងរាជធានី មានចំនួនស្ត្រីជាប់ឆ្នោតច្រើន ដោយឡែកខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ ក៏បានចំនួនភាគរយក្រុមប្រឹក្សាស្ត្រីជិតដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែរ។

ទោះបីជា ចំនួនស្ត្រីឈរឈ្មោះមានការកើនឡើងពីអាណត្តិមួយទៅអាណត្តិមួយក៏ដោយក៏តួលេខនេះនៅតែជាចំនួនតិចតួច ពិសេសស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើនៃបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ បើធៀបនឹងចំនួនបេក្ខជនសរុប (បុរស និងស្ត្រី) ១១១០៥៦នាក់ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣នេះ។ ទោះបីជាមានការជម្រុញ ការបណ្តុះបណ្តាលបង្កើនសមត្ថភាពស្ត្រីរាប់ឆ្នាំ និងមានការអំពាវនាវយ៉ាងណាក៏ដោយក៏បេក្ខ-ជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ មានចំនួនតិចតួចបំផុតគឺ ៥០១នាក់ (០,៤៥%)នៃបេក្ខជនទាំងអស់។ ការបោះឆ្នោតឆ្នាំ២០១២នេះ ស្ត្រីជាប់ឆ្នោតជាមេឃុំស្ត្រីមានចំនួន ៩៥នាក់ (៥.៨១% នៃមេឃុំ-ចៅសង្កាត់សរុប ១៦៣៣ឃុំ-សង្កាត់) ក្នុងនោះ មេឃុំស្ត្រីនៅឃុំដាច់ស្រយាលមានចំនួន ១៦នាក់(១៦,៨៤%នៃមេឃុំស្ត្រី) ស្ត្រីមេឃុំថ្មីជាស្ត្រីវ័យក្មេងមាន ៨នាក់ (៨,៤២%នៃមេឃុំស្ត្រី) ហើយមេឃុំស្ត្រីជាជនជាតិដើមភាគតិចមាន ៥នាក់ (៥,២៦%នៃមេឃុំស្ត្រី)។

ខុមហ្វ្រែល បានធ្វើការសិក្សាស្រាវជ្រាវលឿនមួយក្រោយពីការបោះឆ្នោតមួយថ្ងៃ(នៅថ្ងៃទី៤ខែមិថុនាឆ្នាំ២០១២) ចំពោះអ្នកដែលមិនបានទៅបោះឆ្នោត និងពីមូលហេតុដែលមិនបានទៅបោះឆ្នោត។ ក្នុងនោះការសិក្សាស្រាវជ្រាវរកឃើញថា មានស្ត្រីអត់បានបោះឆ្នោតប្រមាណ ៥១,២%បានទៅបោះឆ្នោត ប៉ុន្តែបានជួបឧបសគ្គដែលក្នុងនោះភាគច្រើនគឺរកឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញ និងគ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត។ បើប្រៀបធៀបជាមួយបុរស ស្ត្រីជួបឧបសគ្គជាងព្រោះក្នុងចំណោមស្ត្រីដែលមិនបានទៅបោះឆ្នោតមាន ៣៧% បានលើកឡើងថាចង់ទៅបោះឆ្នោតតែមិនបានទៅបោះឆ្នោតដោយភាគច្រើនមិនបានចុះឈ្មោះបោះឆ្នោត។ មាន១១,៨% ក្នុងចំណោមស្ត្រីដែលមិនបានទៅបោះឆ្នោតបាននិយាយថា ពួកគេមិនចង់ទៅបោះឆ្នោតដែលភាគច្រើនជាប់រវល់កិច្ចការផ្ទះ និងមូលហេតុផ្សេងៗ។

យោងតាមរបាយការណ៍វាយតម្លៃរបស់ខុមហ្វ្រែលស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២ ប្រជាពលរដ្ឋ ជាពិសេសស្ត្រីនៅតែភ័យខ្លាចក្នុងការភ្ជាប់ខ្លួនជាមួយនឹងគណបក្សប្រឆាំងក្រោយមានអំពីហិង្សាខ្លះបានកើតឡើងប្រឆាំងនឹងស្ត្រីដែលជំទាស់នឹងរដ្ឋាភិបាល។ មានបេក្ខជនស្ត្រី និងគណបក្សនយោបាយជាច្រើនបានឱ្យអ្នកសង្កេតការណ៍ដឹងថា ការរើសអើងប្រឆាំងនឹងបេក្ខជនស្ត្រីដែលពួកគេជួបប្រទះ គឺក្នុងពេលដំណើរការតែងតាំងបេក្ខជន និងការបោះឆ្នោតជ្រើសរើសបេក្ខជននៅក្នុងគណបក្ស។ ជាងនេះទៅទៀត បរិយាកាសនយោបាយក្នុងអំឡុងពេលនៃដំណើរការបោះឆ្នោតម្ដងៗ គេសង្កេតឃើញមានការគំរាមកំហែង និងបញ្ហាជាច្រើនទៀតដែលធ្វើឱ្យមានឥទ្ធិពលជាអវិជ្ជមានដល់ស្ត្រី និងធ្វើឱ្យពួកគេរារែកក្នុងការចូលរួមក្នុងកិច្ចការនយោបាយ។

គណបក្សនយោបាយមួយចំនួន បានលើកឡើងអំពីការប្រឈមក្នុងការរកស្ត្រីមានសមត្ថភាពក្នុងកិច្ចការនយោបាយ និងការងារបោះឆ្នោត។ ប៉ុន្តែជាក់ស្តែង បើទោះបីជាស្ត្រីជាច្រើនត្រូវបានបណ្ដុះបណ្ដាលអំពីភាពជាអ្នកដឹកនាំក្នុងកិច្ចការនយោបាយ និងការងារបោះឆ្នោតដោយអង្គការសង្គមស៊ីវិល។ គណបក្សនយោបាយបានទទួលយកស្ត្រីទាំងនោះ ទៅឈរឈ្មោះឱ្យបានជាប់ឆ្នោតឃុំ-សង្កាត់ នោះបានតែ ១/៣ នៃចំនួនស្ត្រីបានទទួលការហ្វឹកហ្វឺន។ អង្គការសង្គមស៊ីវិលបានបញ្ជូនបញ្ជីឈ្មោះស្ត្រីជាច្រើននាក់ដែលខ្លួនបានបណ្ដុះបណ្ដាល និងហ្វឹកហាត់រួចទៅគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភាដើម្បីឈរឈ្មោះជាបេក្ខជន ជាក់ស្តែង ខុមហ្វ្រែលបានបញ្ជូនបញ្ជីឈ្មោះស្ត្រីចំនួន ៥៤០នាក់ ប៉ុន្តែជាលទ្ធផល គណបក្សបានឱ្យស្ត្រីទាំងនោះឈរឈ្មោះចំនួនតែ ១៤៨នាក់ (២៧,៤០%)។ ដូចគ្នានេះ អង្គការអមរា ក្នុងឆ្នាំ២០១២ បានបណ្ដុះបណ្ដាលសកម្មជននយោបាយស្ត្រី ២០៧នាក់ តែមាន ៩៦នាក់(៤៦.៣៧%) បានឈរឈ្មោះ និងជាប់ឆ្នោត។ កត្តាផ្សេងទៀតត្រូវបានរកឃើញថា ការជ្រើសរើសបេក្ខជនស្ត្រីនៅជួរលើនៃបញ្ជីបេក្ខជនឈរឈ្មោះគឺជាការប្រឆាំងទៅនឹងបេក្ខភាពបុរស។

គណបក្សខ្លះយល់ថា ការដាក់បេក្ខជនមេឃុំ/ចៅសង្កាត់ជាស្ត្រីគឺ ពុំសូវទាក់ទាញអ្នកបោះឆ្នោត ព្រោះអាចមិនមែនជាទម្លាប់ជម្រើសរបស់ប្រជាពលរដ្ឋខ្មែរទេ។ ការទុកចិត្តទៅលើស្ត្រីជាមេឃុំអាចនៅមានកម្រិតក្នុងការគ្រប់គ្រងបញ្ហាសន្តិសុខ និងភាពជាអ្នកដឹកនាំឃុំ-សង្កាត់។ គណបក្សនយោបាយខ្លះដូចជា គណបក្សសិទ្ធិមនុស្សបានលើកឡើងអំពីការជ្រើសរើសបេក្ខជនឬបេក្ខនារី សម្រាប់បញ្ជីបេក្ខជននៃគណបក្សតាមគោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុង ដែលសមាជិកគណបក្សតាមមណ្ឌលឃុំ-សង្កាត់នីមួយៗ ជាអ្នកបោះឆ្នោតទុកចិត្តបេក្ខជនភាពទាំងនោះសម្រាប់បញ្ជីបេក្ខជននៃគណបក្សរបស់ខ្លួន។ ការប្រើប្រាស់គោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុងគណបក្សក៏បានបង្កើតការប្រឈមមួយសម្រាប់បេក្ខភាពនារីដែលសមាជិកបក្សមិនបានទុកចិត្តបោះជូនបេក្ខភាពនារី។ ហេតុដូចនេះ គណបក្សសិទ្ធិមនុស្សមានបេក្ខនារីជាប់ឆ្នោតនៅបញ្ជីខាងលើគឺតិចបំផុត(១.៥០%)។ គណបក្សប្រជាជនកម្ពុជា ក៏មានដំណើរការជ្រើសរើសបេក្ខភាពសម្រាប់បញ្ជីបេក្ខជននៃគណបក្ស តាមគោលការណ៍ការបោះឆ្នោតពីសមាជិកខ្លួននៅមណ្ឌលឃុំ-សង្កាត់និមួយៗ ប៉ុន្តែលទ្ធផលនៃការបោះឆ្នោតនោះមិនបានបង្ហាញនៅឃុំ-សង្កាត់ឱ្យសមាជិកជាអ្នកបោះឆ្នោតនេះបានដឹងទេ។ លទ្ធផលនៃការបោះឆ្នោតត្រូវបានពិនិត្យ ហើយសម្រេចរើសបេក្ខជន និងបេក្ខនារីដាក់ក្នុងបញ្ជីបេក្ខជននៃគណបក្សនៅគណបក្សថ្នាក់លើយ៉ាងហោចណាស់នៅកម្រិតស្រុក/ខណ្ឌ។ ចំណែកគណបក្សសមរង្ស៊ីបានផ្ដល់ការសម្រេចក្នុងការជ្រើសរើសបេក្ខភាពទៅគណបក្សថ្នាក់មូលដ្ឋាន ប៉ុន្តែមានអន្តរាគមន៍ពីថ្នាក់ដឹកនាំចលនាស្ត្រីចំពោះការជ្រើសរើសបេក្ខជន-បេក្ខនារីសម្រាប់បញ្ជីបេក្ខជននៃគណបក្ស។ នីតិវិធីដោយមានអន្តរាគមន៍ពីរចនាសម្ព័ន្ធគណបក្សថ្នាក់លើ រួមទាំងគោលនយោបាយ ក៏អាចបង្កើន

ចំនួនបេក្ខនារី ដែលអាចជាប់ឆ្នោតបានច្រើន ដូចជា គណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ី។ ជាក់ស្តែង លោកជំទាវ **មូរ សុខហួរ** តំណាងរាស្ត្រគណបក្សសមរង្ស៊ី បានពន្យល់ពីករណីមេឃុំស្ត្រីជាប់ឆ្នោតថ្មី កញ្ញា **តឹក នីម** ថា គណបក្សសមរង្ស៊ី គឺមានចេតនាផ្តល់ឱកាសដល់ កញ្ញា តឹក នីម ជាបេក្ខភាពលេខរៀងទីមួយនៃបញ្ជីបេក្ខជន។ កញ្ញា តឹក នីម បានជាប់ឆ្នោតជាមេឃុំស្ត្រីវ័យក្មេងនៅឃុំដែលមានទំនាស់ដីធ្លីច្រើន (ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ) បើទោះបីជា កញ្ញា តឹក នីម គ្មានបទពិសោធន៍ក្នុងកិច្ចការនយោបាយ និងមនុស្សប្រុសនៅទីនោះមានពិសោធន៍ខាងនយោបាយធ្វើក៏ដោយ។ (នេះបើយោងតាមកិច្ចពិភាក្សាតុមូលស្តីពីភាពជោគជ័យ និងការប្រឈមរបស់ស្ត្រីចំពោះលទ្ធផលបោះឆ្នោតនៅឃុំ-សង្កាត់ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២)។

ជាក់ស្តែងមាន ៧គណបក្សដែលបានទទួលអាសនៈ ដោយក្នុងនោះចំនួនអាសនៈភាគច្រើនដែលបានឈ្នះដោយគណបក្សប្រជាជនកម្ពុជា ២១,៤៨% បានទៅស្ត្រីជាភាគរយខ្ពស់បំផុតនៃតំណាងស្ត្រីក្នុងចំណោមគណបក្សទាំងអស់។ បេក្ខជនស្ត្រីនៃគណបក្សប្រឆាំងធំ គណបក្សសមរង្ស៊ី បានជាប់ឆ្នោតភាគរយទីពីរនៃអាសនៈដែលបានបែងចែកទៅដល់គណបក្សរបស់ខ្លួន ១១.០០% ។ គណបក្ស៣ផ្សេងទៀត ស្ត្រីជាប់ឆ្នោតមានចំនួនតិចតួច រាប់បញ្ចូលគណបក្សនរោត្តម-រណឫទ្ធិ បានទទួល៥.៧៧% គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន៣.៣១% ចំណែកគណបក្សសិទ្ធិមនុស្សជាគណបក្សប្រឆាំងទីពីរបានដាក់ស្ត្រីឱ្យជាប់ឆ្នោតបានតែ ១.៥០% ឬចំនួន ១២នាក់ នៃចំនួនសរុប ៨០០ក្រុមប្រឹក្សាឃុំ-សង្កាត់។ ចុងក្រោយ គណបក្សពីរ មិនបានទទួលអាសនៈសម្រាប់ស្ត្រី មានដូចជា គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងគណបក្សសញ្ជាតិកម្ពុជា។

គណបក្សនយោបាយ ៥ ដែលចូលរួមប្រកួតប្រជែងក្នុងឃុំគោលដៅទាំង៥ ក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ គឺគណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តមរណឫទ្ធិ បានដាក់បេក្ខនារីឈរឈ្មោះតែ ១៨%(៧៣នាក់) នៃបេក្ខជនឈរឈ្មោះសរុប ៤០៣នាក់ ក្នុងនោះស្ត្រីឈរឈ្មោះនៅលេខរៀងទី៣ ចំនួន ៤នាក់ (៥,៤៧%) និងលេខរៀងទី៤ ចំនួន ៤នាក់ (៥,៤៧%)។ ជាការពិត បើចំនួនបេក្ខនារីមានច្រើននៅលេខរៀងខាងលើនៃបញ្ជីបេក្ខជននោះទើបមានស្ត្រីជាប់ឆ្នោតច្រើន។ លទ្ធផលសង្កេតបានបង្ហាញថា ក្នុងអំឡុងពេលឃោសនាគណបក្សនយោបាយទាំង៥ សុទ្ធតែបានលើកយកបញ្ហាស្ត្រី និងកុមារដើម្បីដោះស្រាយក្នុងអាណត្តិទី៣នេះ។ គោលនយោបាយទាក់ទងនឹងស្ត្រីបានទទួលដោយគណបក្សនយោបាយភាគច្រើន តែមិនត្រូវបានផ្សព្វផ្សាយញឹកញាប់ជាសាធារណៈ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ខ្វះសមភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ។

គណបក្សនយោបាយជាច្រើននៅតែចង់បានបេក្ខជនស្ត្រីដែលមានសមត្ថភាព និងទាមទារជំនាញនយោបាយបន្ថែមទៀតសម្រាប់ស្ត្រីដែលត្រូវឈរឈ្មោះជាបេក្ខជន។ បន្ថែមលើការពង្រឹងសមត្ថភាព ក្រុមអង្គការសង្គមស៊ីវិលមួយមានឈ្មោះថា "ក្រុមការងារស្ត្រីដើម្បីទាំងអស់គ្នា" យល់ឃើញថា ការងារលើកកម្ពស់សិទ្ធិស្ត្រីក្នុងកិច្ចការនយោបាយគណបក្សនយោបាយ ត្រូវមានគោលនយោបាយក្នុងការរៀបចំបញ្ជីបេក្ខជនឈរឈ្មោះឆ្លាស់គ្នារវាងបុរស និងស្ត្រី ឬនៅលេខរៀងខាងលើចំនួន៣០% ធ្វើយ៉ាងណាផ្តល់ឱកាសឱ្យស្ត្រីមានលទ្ធភាពជាប់ឆ្នោត ព្រមទាំងបានបណ្តុះបណ្តាលស្ត្រីទាំងនោះ ឱ្យមានសមត្ថភាព និងបង្កើនភាពអង់អាចក្លាហានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឃុំ-សង្កាត់។

អនុសាសន៍មួយចំនួនដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចនយោបាយដល់ស្ត្រី ក្នុងនោះរួមមាន ការកំណត់គោលនយោបាយរបស់គណបក្សនយោបាយ ស្តីពីប្រព័ន្ធកូតា ការលុបបំបាត់រាល់ទម្រង់នៃការរើសអើង

ការពង្រឹងសមត្ថភាពសម្រាប់បេក្ខជនស្ត្រីនិងស្ត្រីជាប់ឆ្នោតដើម្បីបង្កើនភាពជឿជាក់ និងប្រសិទ្ធភាពក្នុងការងារក្រោយពេលជាប់ឆ្នោត ការបង្កើតបរិយាកាសនយោបាយល្អសម្រាប់ស្ត្រីនិងការចែករំលែកព័ត៌មានពីសារៈសំខាន់របស់ស្ត្រីក្នុងវិស័យនយោបាយ។

"ប្រព័ន្ធកូតា" ជាដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយដែលអាចលើកទឹកចិត្តឱ្យគ្រប់គណបក្សនយោបាយដាក់បេក្ខជនស្ត្រីក្នុងបញ្ជីបេក្ខជនរបស់គណបក្ស។ ការលើកទឹកចិត្តដើម្បីបង្កើតប្រព័ន្ធកូតាក្នុងគណបក្សនយោបាយក៏អាចត្រូវបានបង្កើតក្នុងក្របខណ្ឌច្បាប់ដែរ និយាយដល់ការធ្វើវិសោធនកម្មច្បាប់សម្រាប់ការបោះឆ្នោត។ វិសោធនកម្មច្បាប់នេះកែលម្អបន្ថែមលក្ខណៈនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឱ្យមានប្រព័ន្ធកូតា ៣០% និងដាក់ឆ្លាស់សម្រាប់បេក្ខជន បុរស ឬស្ត្រី និងបង្កើតគោលនយោបាយសម្រាប់រដ្ឋផ្តល់មូលនិធិដល់គណបក្សនយោបាយនយោបាយណាដែលគោរព និងអនុវត្តតាមច្បាប់នេះ។ មូលនិធិរបស់រដ្ឋ ត្រូវបានអនុម័តចេញពីថវិកាជាតិដើម្បីឱ្យទៅគណបក្សនយោបាយសម្រាប់ធ្វើការបណ្តុះបណ្តាលដល់បេក្ខជន ពិសេសបេក្ខនារីក្នុងកិច្ចការងារនយោបាយ និងការបោះឆ្នោត។

ក្រៅពីវិធានការច្បាប់ ការលើកទឹកចិត្តដល់គណបក្សនយោបាយ និងវិធានការគាំទ្រដល់បេក្ខនារីក៏សំខាន់ណាស់ដែរ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអំពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងការងារនយោបាយ ការងារបោះឆ្នោត និងការងារសម្រេចចិត្ត។ អង្គការសង្គមស៊ីវិលក៏បន្តការឃ្លាំមើល និងអង្កេតអំពីស្ថានភាពសកម្មជនស្ត្រីនយោបាយ និងមន្ត្រីជាប់ឆ្នោតស្ត្រី ថាតើពួកគេបានបំពេញតួនាទីភារកិច្ចស្របតាមច្បាប់ឬទេ ? ថាតើមានការរើសអើង និងអំពើហិង្សា ការបំភិតបំភ័យ គម្រាមកំហែងដល់ពួកគេទាំងនោះឬទេ ?

ជាសរុប "មានភាពប្រសើរឡើងតិចតួចមិនទាន់ដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជាចំពោះចំនួនកំណើនស្ត្រីចូលរួមក្នុងកិច្ចការនយោបាយនិងជាប់ឆ្នោត ហើយក៏មានការធ្លាក់ចុះវិសមភាព និងការរើសអើងយេនឌ័រ"។ មានការប្រឈម និងបញ្ហាជាច្រើនទៀតដែលត្រូវកែលម្អ រួមទាំង គុណភាពនៃការចូលរួមរបស់ស្ត្រី។ នៅមានឧបសគ្គដែលរារាំងដល់ការអនុវត្តសមភាពយេនឌ័រជាតំណាងជាប់ឆ្នោត មូលហេតុចំបង ព្រោះប្រទេសកម្ពុជាខ្វះគោលការណ៍ជាក់លាក់ជាលាយលក្ខណ៍អក្សរ ខ្វះយន្តយន្តការពិសេសដើម្បីគាំទ្រ និងផ្តល់ឱកាសដែលជាវិធានការណ៍សម្រាប់ស្ត្រីចូលរួមលើគ្រប់វិស័យស្របតាមអនុសញ្ញាអន្តរជាតិស៊ី-ដ។ ការប្រឈមក្នុងការបង្កើនស្ត្រីចូលរួមនយោបាយក្នុងបោះឆ្នោតឆ្នាំ២០១៣ខាងមុខ មានកម្រិតទាបនៃការយកចិត្តទុកដាក់ពីគណបក្សនយោបាយ។ គណបក្សនយោបាយសំខាន់ដែលមានអាសនៈនៅរដ្ឋសភា ហាក់ផ្តោតសំខាន់លើកិច្ចការប្រកួតប្រជែងនយោបាយ និងការខិតខំដោះស្រាយទំនាស់នយោបាយច្រើនជាង។ កិច្ចពិភាក្សាតុមូលនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ បានដាក់សំណួរ ទៅគណបក្សប្រឆាំងថា "តើអ្វីជាគោលនយោបាយរបស់គណបក្សក្នុងការលើកស្ទួយស្ត្រីចូលរួមនយោបាយ និងបង្កើនចំនួនស្ត្រីជាប់ឆ្នោតថ្នាក់ជាតិខាងមុខ?" ចម្លើយសំខាន់នោះគឺ ការយកចិត្តទុកដាក់ "ការបង្រួបបង្រួមគណបក្សប្រឆាំង គោលការណ៍ប្រជាធិបតេយ្យ និងបញ្ហាជាតិធំៗ" ប៉ុន្តែបញ្ហាស្ត្រីមិនបានក្លាយជាបញ្ហាអាទិភាព។ ចំណែកគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) ហាក់មិនចាប់អារម្មណ៍ក្នុងការចូលរួមពិភាក្សាទេ៕